# ព្រះរាជក្រឹត្យ

## ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋាន
## នៃសមាជិក_សមាជិកាព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

នស/រកត/០៧០១/២៣១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតព្រឹទ្ធសភា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងថ្នាក់ដឹកនាំជាន់ខ្ពស់ នៃព្រឹទ្ធសភា នីតិកាលទី ១
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៤ ចុះថ្ងៃ ទី ១១ ខែ មិនា ឆ្នាំ ១៩៩៩, ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៦៨ ចុះថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ១៩៩៩ និង ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៦៩ ចុះថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងសមាជិកព្រឹទ្ធសភា សំរាប់នីតិកាលទី ១
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំរបស់ប្រធានព្រឹទ្ធសភា ។

# ត្រាស់បង្គាប់

**មាត្រា១ ..**

ត្រូវបានបង្កើតសញ្ញាសក្តិ និងឯកសណ្ឋានសំរាប់សំគាល់សមាជិក-សមាជិកាព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២ ..**

សញ្ញាសក្តិ រួមមាន សក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវទាំងសងខាង ។

ឯកសណ្ឋាន រួមមាន ឯកសណ្ឋានផ្លូវការ និងឯកសណ្ឋានប្រពៃណីជាតិ ។

**មាត្រា៣ ..**

ការប្រើប្រាស់ឯកសណ្ឋានសំរាប់សមាជិក-សមាជិកាព្រឹទ្ធសភាត្រូវបានកំណត់ដូចខាងក្រោម :

- ឯកសណ្ឋានផ្លូវការ សំរាប់ប្រើប្រាស់ក្នុងឱកាសទិវាបុណ្យជាតិ ពិធីផ្លូវការផ្សេងៗទៀតរបស់រដ្ឋ និងរបស់ព្រឹទ្ធសភា ជាពិសេស ក្នុងពិធីបើកជាផ្លូវការនៃសម័យប្រជុំនីមួយៗរបស់ព្រឹទ្ធសភា បន្ទាប់ពីវិស្សមកាល ។
- ឯកសណ្ឋានប្រពៃណីជាតិ សំរាប់ប្រើប្រាស់ក្នុងឱកាសទិវាបុណ្យប្រពៃណីជាតិ និងសាសនា ដែលប្រារព្ធនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម និងទីកន្លែងផ្សេងៗ ជាពិសេស ក្នុងឱកាសពិធីបើកជាផ្លូវការនៃនីតិកាលនីមួយៗរបស់ព្រឹទ្ធសភា ។

សមាជិក-សមាជិកាព្រឹទ្ធសភា ប្រើប្រាស់ឯកសណ្ឋានទាំងពីរប្រភេទខាងលើនេះទៅតាមការកំណត់ក្នុងសេចក្តីអញ្ជើញជាផ្លូវការរបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ឬរបស់ក្រសួងព្រះបរមរាជវាំង ឬរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឬរបស់អគ្គលេខាធិការដ្ឋានរដ្ឋសភា ។

**មាត្រា៤ .. អំពីសញ្ញាសក្តិ**

សញ្ញាសក្តិនៃសមាជិក-សមាជិកាព្រឹទ្ធសភាត្រូវបានកំណត់ដូចតទៅ :

**១. សំរាប់ប្រធាន អនុប្រធានព្រឹទ្ធសភា និងប្រធានគណៈកម្មការនៃព្រឹទ្ធសភា**

**ក-__សក្តិស្មា__:** មានផ្ទៃកម្ពីពណ៌ខ្មៅ រចនាគុបតែងដោយក្បាច់អង្គរពណ៌មាសចំកណ្តាល ។ នៅពីខាងលើក្បាច់អង្គរ មានសញ្ញាព្រឹទ្ធសភាពណ៌មាស ហើយនៅពីខាងលើសញ្ញាព្រឹទ្ធសភា មានឡេវមួយគ្រាប់រូបព្រះសង្ខាពណ៌មាស ។ មានពួរវេញមួយខ្សែពណ៌មាស ព័ទ្ធជុំវិញរូបភាពទាំង៣នេះ ។ នៅផ្នែកខាងក្រៅពួរវេញនេះ មានរាយជាក្បាច់ចក(មូល១) ជាល់អជរជាយ ។ ដោយឡែក នៅបាតក្រោមនៃសក្តិមានក្បាច់ចក (មូល១) ធំបី ជានិមិត្តសញ្ញាតំណាងបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ ។ នៅតាមគែមនៃសក្តិខាងក្រៅ៕ភ.

មានក្បាច់ជរជាយជាពួរវេញពណ៌មាស បីឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិប្រធានព្រឹទ្ធសភា ពីរឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអនុប្រធានព្រឹទ្ធសភា និងមួយឆ្នូត សំរាប់សំគាល់ឋានន្តរសក្តិប្រធានគណៈកម្មការនៃព្រឹទ្ធសភា ។

ខ្នាតសក្តិស្មាត្រូវបានកំណត់ដូចខាងក្រោមនេះ :

- បាតក្រោមប្រវែង ៥.៥០ សង្ទីម៉ែត្រ
- ទទឹងមុខកាត់ផ្នែកខាងលើប្រវែង ៤.៥។ សង្ទីម៉ែត្រ មានរាងកោងជាមុំទាល
- បណ្តោយពីលើដល់បាតក្រោមប្រវែង ១៣ សង្ទីម៉ែត្រ

**ខ_សក្តិចុងកអាវ** : មានផ្ទៃកម្ទីពណ៌ខ្មៅ រចនាតុបតែងដោយក្បាច់អង្គរពណ៌មាស និងមានសញ្ញាព្រឹទ្ធសភានៅខាងដើម ។ មានឆ្នូតពួរវេញពណ៌មាសមួយឆ្នូតព័ទ្ធជុំវិញក្បាច់អង្គរ និងសញ្ញាព្រឹទ្ធសភា ។ នៅផ្នែកខាងមុខ ក្រៅរង្វង់ឆ្នូតពួរវេញនេះ មានកួរស្រូវពណ៌មាសមួយកួរ មាន៩គ្រាប់ជានិមិត្តសញ្ញានៃសេដ្ឋកិច្ចកម្ពុជា និងប្រជាពលរដ្ឋខ្មែរ ជាង៩០%ជាកសិករ ។ នៅផ្នែកខាងលើនៃសក្តិ មានក្បាច់ចក(មូល១)រាយជាជួរលំអជរជាយ ។ ដោយឡែក នៅគែមខាងមុខ និងខាងលើនៃសក្តិចុងកអាវនេះ មានឆ្នូតពណ៌មាសបីជាសញ្ញាសំគាល់ឋានន្តរសក្តិប្រធានព្រឹទ្ធសភា ពីរឆ្នូតសំគាល់ឋានន្តរសក្តិអនុប្រធានព្រឹទ្ធសភា និងមួយឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិប្រធានគណៈកម្មការនៃព្រឹទ្ធសភា ។

ខ្នាតសក្តិចុងកអាវ ត្រូវបានកំណត់ដូចខាងក្រោមនេះ :

- មានរាងជាប្រលេឡូក្រាម
- បណ្តោយប្រវែង ១១ សង្ទីម៉ែត្រ
- ទទឹងប្រវែង ៣.៥០ សង្ទីម៉ែត្រ

**គ_សក្តិចុងដៃអាវទាំងសងខាង** : មានផ្ទៃកម្ទីពណ៌ខ្មៅ រចនាតុបតែងដោយក្បាច់អង្គរពណ៌មាស មានក្បាច់ចកពណ៌មាសរាយលំអជរជាយពីខាងលើ និងចំហៀងទាំងសងខាង ។ ជាពិសេស មានឆ្នូតពណ៌មាសបីតាមគែមសក្តិខាងលើ និងចំហៀងសងខាងសំរាប់សំគាល់ឋានន្តរសក្តិប្រធានព្រឹទ្ធសភា ពីរឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអនុប្រធានព្រឹទ្ធសភា និងមួយឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិប្រធានគណៈកម្មការនៃព្រឹទ្ធសភា ។ ដោយឡែក នៅជុំវិញក្បាច់អង្គរ មានពួរវេញមួយខ្សែព័ទ្ធជុំវិញផងដែរ ។

ខ្នាតសក្តិចុងដៃអាវទាំងសងខាង ត្រូវបានកំណត់ដូចខាងក្រោមនេះ :

- មានរាងបួនជ្រុងទ្រវែង
- បណ្តោយប្រវែង ៣២ សង្ទីម៉ែត្រ ចំពោះបុរស និង ២៥ ទៅ ២៨ សង្ទីម៉ែត្រចំពោះនារី អាស្រ័យលើមាឌ ម.រ.

- ទទឹងប្រវែង ៩ សង់ទីម៉ែត្រ

រូបគំនូរសក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវ សំរាប់ប្រធានព្រឹទ្ធសភា មានគំរូដូចក្នុងឧបសម្ព័ន្ធទី ១ សំរាប់អនុប្រធានព្រឹទ្ធសភា មានគំរូដូចក្នុងឧបសម្ព័ន្ធទី២ និងសំរាប់ប្រធានគណៈកម្មការនៃព្រឹទ្ធសភា មានគំរូ ដូចក្នុងឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យនេះ ។

## ២. សំរាប់អនុប្រធានគណៈកម្មការ និងសមាជិក-សមាជិកាព្រឹទ្ធសភាដទៃទៀត

**ក-សក្តិស្មា:** មានផ្ទៃកម្ចីពណ៌ខ្មៅ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាសចំកណ្តាល ។ នៅពីខាងលើក្បាច់ភ្ញីទេស មានសញ្ញាព្រឹទ្ធសភាពណ៌មាស ហើយនៅពីខាងលើសញ្ញាព្រឹទ្ធសភា មានឡេវមួយគ្រាប់ រូបព្រះសង្ហាពណ៌មាស ។ មានក្ងួរវេញមួយខ្សែពណ៌មាស ព័ទ្ធជុំវិញរូបភាពទាំង៣នេះ ។ នៅផ្នែកខាងក្រៅពួរវេញនេះ មានរាយជាក្បាច់ចក(មូល១) ជាល់អជរជាយ ។ ដោយឡែក នៅបាតក្រោមនៃសក្តិមានក្បាច់ឆក (មូល១) ធំបី ជានិមិត្តសញ្ញាតំណាងបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ ។ នៅតាមគែមនៃសក្តិខាងក្រៅ មានក្បាច់ជរជាយជាពួរវេញពណ៌មាស ពីរឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិអនុប្រធានគណៈកម្មការ និងមួយឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិសមាជិក-សមាជិកា នៃព្រឹទ្ធសភា ។

ខ្នាតសក្តិស្មាត្រូវបានកំណត់ដូចខាងក្រោមនេះ :

- បាតក្រោមប្រវែង ៥.៥០ សង់ទីម៉ែត្រ
- ទទឹងមុខកាត់ផ្នែកខាងលើប្រវែង ៤.៥០ សង់ទីម៉ែត្រ មានរាងកោងជាមុំទាល
- បណ្តោយពីលើដល់បាតក្រោមប្រវែង ១៣ សង់ទីម៉ែត្រ

**ខ-សក្តិចុងកអាវ** : មានផ្ទៃកម្ចីពណ៌ខ្មៅ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាស និងមានសញ្ញាព្រឹទ្ធសភានៅខាងដើម ។ មានឆ្នូតពួរវេញពណ៌មាសមួយឆ្នូតព័ទ្ធជុំវិញក្បាច់ភ្ញីទេស និងសញ្ញាព្រឹទ្ធសភា។ នៅផ្នែកខាងមុខ ក្រៅរង្វង់ឆ្នូតពួរវេញនេះ មានកួរស្រូវពណ៌មាសមួយកួរ មាន៩គ្រាប់ជានិមិត្តសញ្ញានៃសេដ្ឋកិច្ចកម្ពុជា និងប្រជាពលរដ្ឋខ្មែរ ជាង៩០%ជាកសិករ ។ នៅផ្នែកខាងលើនៃសក្តិមានក្បាច់ចក(មូល១)រាយជាជូរលំអជរជាយ ។ ដោយឡែក នៅគែមខាងមុខ និងខាងលើនៃសក្តិចុងកអាវនេះ មានឆ្នូតពណ៌មាសពីរជាសញ្ញាសំគាល់ឋានន្តរសក្តិអនុប្រធានគណៈកម្មការ និងមួយឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិសមាជិក-សមាជិកា នៃព្រឹទ្ធសភា ។

ខ្នាតសក្តិចុងកអាវ ត្រូវបានកំណត់ដូចខាងក្រោមនេះ :

- មានរាងជាប្រលេឡូក្រាម
- បណ្តោយប្រវែង ១១ សង់ទីម៉ែត្រ ៸ស.ក.

- ទទឹងប្រវែង ៣.៥០ សង្ទីម៉ែត្រ

**ឥ_សក្តិចុងដៃអាវទាំងសងខាង** : មានផ្ទៃកម្ទីពណ៌ខ្មៅ រចនាគុបតែងដោយក្បាច់ភ្ញីទេសពណ៌មាស មានក្បាច់ចកពណ៌មាសរាយលំអជរជាយពីខាងលើ និងចំហៀងទាំងសងខាង ។ ជាពិសេស មានឆ្នូតពណ៌មាសពីរតាមគែមសក្តិ ខាងលើ និងចំហៀងទាំងពីរសំរាប់សំគាល់ឋានន្តរស័ក្តិអនុប្រធានគណៈកម្មការ និងមួយឆ្នូតសំរាប់សំគាល់ឋានន្តរសក្តិសមាជិក-សមាជិកា នៃព្រឹទ្ធសភា ។ ដោយឡែក នៅជុំវិញក្បាច់ភ្ញីទេស មានពួរវេញមួយខ្សែព័ទ្ធជុំវិញផងដែរ ។

ខ្នាតសក្តិចុងដៃអាវទាំងសងខាង ត្រូវបានកំណត់ដូចខាងក្រោមនេះ

- មានរាងបួនជ្រុងទ្រវែង
- បណ្តោយប្រវែង ៣២ សង្ទីម៉ែត្រ ចំពោះបុរស និង ២៥ ទៅ២៨ សង្ទីម៉ែត្រចំពោះនារីអាស្រ័យលើមាឌ
- ទទឹងប្រវែង ៩ សង្ទីម៉ែត្រ

រូបគំនូរសក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវ សំរាប់អនុប្រធានគណៈកម្មការព្រឹទ្ធសភា មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យនេះ ។ រូបគំនូរសក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវ សំរាប់សមាជិក-សមាជិកាព្រឹទ្ធសភា មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យនេះ ។

ដោយឡែក សក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវទាំងសងខាងរបស់នារី មានទំហំតូចដូចខាងក្រោមនេះ :

- សក្តិស្មាអាចមានទំហំ ៨០%, ៨៥%, ៩០% នៃទំហំសក្តិស្មារបស់បុរស អាស្រ័យលើមាឌរបស់នារី
- សក្តិចុងដៃអាវ អាចមានទំហំទទឹងស្មើនឹង ៧០% ទៅ ៧៥% នៃទំហំទទឹងសក្តិចុងដៃអាវរបស់បុរស អាស្រ័យលើមាឌរបស់នារី
- សក្តិចុងកអាវ មានទំហំ ៣ សង្ទីម៉ែត្រ ទៅ ៣.៥ សង្ទីម៉ែត្រ អាស្រ័យលើមាឌរបស់នារី

**មាត្រា៥ .- អំពីឯកសណ្ឋាន**

ឯកសណ្ឋានសំរាប់សមាជិក-សមាជិកាព្រឹទ្ធសភា ត្រូវបានកំណត់ដូចខាងក្រោម :

**១_ ឯកសណ្ឋានផ្លូវការ**

**ក_ចំពោះបុរស** :ល.ក.

- អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំ គ្មានផែកខ្នង ចុងកអាវ មានសក្តិតាមឋានន្តរសក្តិ មានបន្ទះលើស្មាសំរាប់ដាក់សក្តិ មានហោប៉ៅចោះ មានគំរបរាងស្លឹកពោធិ ខាងលើពីរខាងក្រោមពីរ ។ អាវដៃវែង ចុងដៃអាវមានសក្តិ តាមឋានន្តរសក្តិ អាវបិទឡេវមុខ ដោយដាក់ឡេវរូបព្រះសង្ខាចំនួនប្រាំពីរ ។

- ខោជើងវែងពណ៌ស ស្បែកជើងឃ្លុបពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

**ខ_ចំពោះនារី :**

- អាវជីបរាងពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវរបស់បុរស កតាំង គ្មានផែកខ្នង បិទឡេវមុខ ដាក់ឡេវរូបសញ្ញាព្រះសង្ខាចំនួនប្រាំពីរ ។ ចុងកអាវទាំងសងខាង មានសក្តិតាមឋានន្តរសក្តិ មានបន្ទះលើស្មាសំរាប់ដាក់សក្តិ មានហោប៉ៅចោះ មានគំរបរាងស្លឹកពោធិខាងលើពីរខាងក្រោមពីរ ដៃវែងត្រឹមភ្អែកកោលដៃ ចុងដៃអាវមានសក្តិតាមឋានន្តរសក្តិ ។

ឯកសណ្ឋានផ្លូវការមាន ៣ប្រភេទ :

- ប្រើសំពត់សំឡុយអំពីផាមុងពណ៌ព្រីងទុំ ចាក់ជើងអំពីសូត្រ ពណ៌ខ្ចីជាងពណ៌សំពត់ ហៅថា ឯកសណ្ឋានផ្លូវការប្រភេទលេខ ១ ។

- ប្រើសំពត់សំឡុយអំពីផាមួងពណ៌ព្រីងទុំ ចាក់ជើងសែសយពណ៌ប្លាទីនមាស តាមក្បាច់ជរជើងឯកភាពគ្នា ហៅថា ឯកសណ្ឋានផ្លូវការប្រភេទលេខ ២ ។

- ប្រើសំពត់សំឡុយអំពីហូល តាមគោមឯកភាពគ្នា ហៅថា ឯកសណ្ឋានផ្លូវការប្រភេទលេខ ៣ ។

- ស្បែកជើងអេស្កាប៉ាំងឃ្លុបមុខ និងជិតកែងពណ៌ស កាបូបយួរដៃពណ៌ស សំរាប់ពេលព្រឹកដល់ថ្ងៃត្រង់ ។

- ស្បែកជើងអេស្កាប៉ាំងឃ្លុបមុខ និងជិតកែងពណ៌ខ្មៅ កាបូបយួរដៃពណ៌ខ្មៅ សំរាប់ពេលល្ងាច ។

រូបគំនូរឯកសណ្ឋានផ្លូវការសំរាប់សមាជិក-សមាជិកាព្រឹទ្ធសភា មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៦ នៃព្រះរាជក្រឹត្យនេះ ។

**២_ ឯកសណ្ឋានប្រពៃណីជាតិ**

**ក_ចំពោះបុរស :** ន.។.

- អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំ គ្មានផែកខ្នង ចុងកអាវ មានសក្តិតាមឋានន្តរសក្តិ មានបន្ទះលើស្មាសំរាប់ដាក់សក្តិ មានហោប៉ៅចោះ មានគំរបរាងស្លឹកពោធិខាងលើពីរខាងក្រោមពីរ ។ អាវដៃវែង ចុងដៃអាវមានសក្តិតាមឋានន្តរសក្តិ អាវបិទមុខដោយដាក់ឡេវរូបសញ្ញាព្រះសង្ខចំនួនប្រាំពីរ ។

- សំពត់ជាមួងចងក្បិនពណ៌តាមថ្ងៃ ស្បែកជើងឃ្លុបពណ៌ខ្មៅចងខ្សែ ស្រោមជើងពណ៌ខ្មៅដល់ជង្គង់ ។

**ខ_ចំពោះនារី :**

- អាវជីបរាងអំពីក្រណាត់ប៉ាក់ពណ៌ស ដៃវែងត្រឹម៣/៤ កវៀលមូលខាងមុខធ្លាក់ចុះពីក្បាលឆ្អឹងដងកាំបិត ១.៥០ សង្ទីម៉ែត្រ និងត្រង់ស្មា ឃ្លាតពីគល់កប្រមាណ ២.៥០ សង្ទីម៉ែត្រ ទៅ ៣.០០ សង្ទីម៉ែត្រអាស្រ័យទៅតាមមាឌរបស់នារី ។

- ពានាក្រមាអំពីសូត្រ ដែលមានផ្ទៃពណ៌ខ្ចីជាងសំពត់ ឬក្រមាសូត្រពណ៌ស៊ីនួន តាមការកំណត់របស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ឬរបស់ក្រសួងព្រះបរមរាជវាំង ឬរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឬ របស់អគ្គលេខាធិការដ្ឋានរដ្ឋសភា ដោយប្រើកន្លាស់សំរាប់ខ្ទាស់ក្រមាពានាជាកន្លាស់អំពីសញ្ញាព្រឹទ្ធសភា ដែលមានទំហំទទឹង ៥ សង្ទីម៉ែត្រ និង កំពស់ ៧ សង្ទីម៉ែត្រ ។

ឯកសណ្ឋានប្រពៃណីជាតិ មាន ២ ប្រភេទ :

- ឯកសណ្ឋានប្រពៃណីជាតិ ដែលប្រើសំពត់ជាមួងចងក្បិន ពណ៌តាមថ្ងៃ និងពានាក្រមាពណ៌ខ្ចីជាងសំពត់ ហៅថាឯកសណ្ឋានប្រពៃណីជាតិ ប្រភេទលេខ ១ ។

- ឯកសណ្ឋានប្រពៃណីជាតិ ដែលប្រើសំពត់ហូលតាមគោមឯកភាពគ្នា និងពានាក្រមាពណ៌ស៊ីនួន ហៅថាឯកសណ្ឋានប្រពៃណីជាតិ ប្រភេទលេខ ២ ។

- ស្បែកជើងពណ៌ស និង កាបូបយួរដៃពណ៌ស សំរាប់ពេលព្រឹក ដល់ថ្ងៃត្រង់ ។

- ស្បែកជើងពណ៌ខ្មៅ និងកាបូបយួរដៃពណ៌ខ្មៅ សំរាប់ពេលល្ងាច ។

រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសំរាប់សមាជិក-សមាជិកាព្រឹទ្ធសភា មានគំរូដូចក្នុងឧបសម្ព័ន្ធទី៧ នៃព្រះរាជក្រឹត្យនេះ ។ រូបគំនូរកន្លាស់ព្រឹទ្ធសភា មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យនេះ ។/.

**មាត្រា ៦ .-**

ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០១

លេខៈ ១៨០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ាជី តាន់**

ឧបសម្ព័ន្ធទី ១ នៃព្រះរាជក្រឹត្យលេខ..នស/រកត/០៧០១/២៣១
ចុះថ្ងៃទី ១២ ខែកក្កដាឆ្នាំ ២០០១ ស្ដីពីសញ្ញាសក្តិ និងឯកសណ្ឋាននៃ
សមាជិក-សមាជិកាព្រឹទ្ធសភា

## ប្រធានព្រឹទ្ធសភា

សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ



ឧបសម្ព័ន្ធទី ២ នៃព្រះរាជក្រឹត្យលេខ.នស/រកត/០៧០១/២៣១
ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋាននៃ
សមាជិក-សមាជិកាព្រឹទ្ធសភា

# អនុប្រធានព្រឹទ្ធសភា

សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ



ឧបសម្ព័ន្ធទី ៣ នៃព្រះរាជក្រឹត្យលេខ.......................

ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋាននៃ

សមាជិក-សមាជិកាព្រឹទ្ធសភា

## ប្រធានគណៈកម្មការព្រឹទ្ធសភា

សក្តិចុងអាវ



សក្តិស្មា



សក្តិចុងដៃអាវ



ឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យលេខ..........................
ចុះថ្ងៃទី........ខែ........ឆ្នាំ........ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋាននៃ
សមាជិក-សមាជិកាព្រឹទ្ធសភា

## អនុប្រធានគណៈកម្មការព្រឹទ្ធសភា

សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ



ឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យលេខនស/រកត/០៧០១/២៣១
ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋាននៃ
សមាជិក-សមាជិកាព្រឹទ្ធសភា

## សមាជិក-សមាជិកាព្រឹទ្ធសភា

សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ



ឧបសម្ព័ន្ធទី ៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣១ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីសញ្ញាសក្ដិ និងឯកសណ្ឋាននៃសមាជិក-សមាជិកាព្រឹទ្ធសភា ។

## ឯកសណ្ឋានផ្លូវការ



## ឯកសណ្ឋានប្រពៃណីជាតិ



ឧបសម្ព័ន្ធទី ៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៧១
ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋាននៃ
សមាជិក-សមាជិកាព្រឹទ្ធសភា ។

# គន្លាស់សញ្ញាព្រឹទ្ធសភា

ឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣១ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីកន្លាស់សញ្ញាព្រឹទ្ធសភានៃសមាជិក-សមាជិកាព្រឹទ្ធសភា ។ល។

